អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់)
REPRODUCTIVE HEALTH ASSOCIATION OF CAMBODIA (RHAC)

# និន្នាការផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ (សូជី) និងភេទជីវៈសាស្ត្រ

## Sexual Orientation, Gender Identity, Expression (SOGIE), and biological sex

### ការបង្ហាញយេនឌ័រ

**Gender Expression**

គឺជាការបង្ហាញខ្លួនឯងស្របទៅតាមអត្តសញ្ញាណយេនឌ័ររបស់ខ្លួនដោយវិធីផ្សេងៗដូចជា ការតុបតែងខ្លួន និងការជ្រើសរើសម្លៀកបំពាក់ អាកប្បកិរិយា ឬការប្តូរការហៅឈ្មោះ និងសព្វនាមសម្រាប់ហៅខ្លួនឯងជាដើម។

### អត្តសញ្ញាណយេនឌ័រ

**Gender Identity**

គឺជាការកត់សម្គាល់ដឹងនៅក្នុងខួរក្បាល អំពីយេនឌ័ររបស់ខ្លួនថាតើខ្លួនឯងមានយេនឌ័រស្រប ឬក៏មិនស្របជាមួយភេទកំណើតរបស់ខ្លួនកម្រិតណា ឬក៏ដឹងថាខ្លួនមានក្តីរំពឹងចង់ក្លាយទៅជាយេនឌ័រមួយណា។



### និន្នាការផ្លូវភេទ

**Sexual Orientation**

គឺជាទំនោរអារម្មណ៍របស់ខ្លួនទៅលើនរណាម្នាក់ ឬយេនឌ័រណាមួយទាំងការទាក់ទាញផ្លូវកាយ ទំនាក់ទំនងផ្នែកមនោសញ្ចេតនា និងរឿងផ្លូវភេទ។

### ភេទជីវសាស្ត្រ

**Biological sex**

គឺជាកត្តាជីវសាស្ត្រ ដែលកំណត់ឱ្យមានលក្ខណៈខុសគ្នាតាំងពីកំណើតក្នុងផ្ទៃម្តាយ រវាងភេទប្រុស និងភេទស្រី រួមមានដូចជាក្រូម៉ូសូម ការលូតលាស់រូបរាងកាយ និងសរីរាង្គភេទ ដំណើរការប្រព័ន្ធជីវសាស្ត្រក្នុងខ្លួនមនុស្ស (ការផលិតអ័រម៉ូនជាដើម) -ល-។

**LGBTQI+** (អ្នកដែលមាននិន្នាការភេទចម្រុះ) សម្គាល់ឱ្យ ៖

- **Lesbian** ស្ត្រីស្រលាញ់ស្ត្រី
- **Gay** បុរសស្រលាញ់បុរស
- **Bisexual** អ្នកស្រលាញ់ទាំងពីរភេទ (ទាំងបុរស និងស្ត្រី)
- **Transgender** អ្នកប្លែងភេទ
- **Queer** អ្នកដែលមិនទាន់មានអត្តសញ្ញាណយេនឌ័រច្បាស់លាស់
- **Intersex** អន្តរភេទ
- **(+)** ៖ បញ្ជាក់ថា ក្រៅពីនេះនៅមានយេនឌ័រផ្សេងទៀត ។




### អត្តសញ្ញាណយេនឌ័រ

- ✓ មានភាពជាក្មេងប្រុស ឬបុរស
- ✓ មានភាពជាក្មេងស្រី ឬស្ត្រី
- ✓ មានទាំងពីរ (ក្មេងប្រុស និងក្មេងស្រី) ឬផ្សេងទៀត

### ការបង្ហាញយេនឌ័រ

- ✓ បង្ហាញរូបភាពនៃខ្លួនឯងក្នុងសភាពជានារី
- ✓ បង្ហាញរូបភាពនៃខ្លួនឯងក្នុងសភាពជាបុរស
- ✓ បង្ហាញរូបភាពនៃខ្លួនឯងខ្លួនឯងក្នុងសភាពជានារីផង និងជាបុរសផង ឬផ្សេងទៀត

### និន្នាការផ្លូវភេទ

- ✓ ភេទដូចគ្នា
- ✓ ភេទផ្ទុយគ្នា
- ✓ ទាំងពីរភេទ (បុរស និងស្ត្រី) ឬផ្សេងទៀត

### ភេទជីវៈសាស្ត្រ

- ✓ ភេទប្រុស
- ✓ ភេទស្រី
- ✓ អន្តរភេទ

យោងតាម៖ Genderbread Person V4

| ពាក្យគន្លឹះ | សេចក្តីពន្យល់ | សម្គាល់ |
| --- | --- | --- |
| អត្តសញ្ញាណយេនឌ័រ<br>**(Gender identify)**<br> | គឺជាអារម្មណ៍នឹងនៅក្នុងខួរក្បាល និងកំណត់ដោយបុគ្គលខ្លួនឯងក្នុងការប្រកាន់យកយ៉ាងស៊ីជម្រៅអំពីយេនឌ័ររបស់ខ្លួនក្នុងនាមជាបុរស ឬស្ត្រី ឬជាយេនឌ័រណាមួយផ្សេង ដែលវាមិនមែនជាអ្វីៗ ដែលអ្នកដទៃគិតជំនួស ឬសម្គាល់អ្នកឱ្យនោះទេ។ | អត្តសញ្ញាណយេនឌ័រអាចស្រប និងអាចមិនស្របជាមួយនឹងភេទពីកំណើតរបស់ខ្លួនដូចជា៖<br>⇨ **យេនឌ័រប្រប (Cis gender)** ៖ ជាអ្នកដែលមានអារម្មណ៍ខាងក្នុងស្របទៅនឹងភេទកំណើតរបស់ខ្លួន។<br>⇨ **អ្នកប្តូរយេនឌ័រ (Transgender)** ៖ អ្នកដែលមានអារម្មណ៍ខាងក្នុងផ្ទុយពីភេទកំណើតរបស់ខ្លួន ។<br>⇨ **ទ្វិកយេនឌ័រ (Bigender)** ៖ ជាអ្នកដែលមានអារម្មណ៍ជាបុរសផង និងជាស្ត្រីផង។ |
| ការបង្ហាញយេនឌ័រ<br>**(Gender Expression)**<br> | គឺជាពេលវេលាមួយ ដែលអ្នកសម្រេចចិត្តបង្ហាញអត្តសញ្ញាណយេនឌ័រពិតរបស់អ្នកទៅកាន់ពិភពខាងក្រៅដោយបើកចំហតាមរយៈវិធីផ្សេងៗដូចជាការរៀបចំខ្លួន ការស្លៀកពាក់ របៀបនៃការប្រព្រឹត្ត ការប្តូរឈ្មោះ និង ការកំណត់សព្វនាម ( អ្នកនាង ឬលោក) ឱ្យខ្លួនឯងជាដើម។ | **ការផ្លាស់ប្តូរ (Transition)** គឺជាដំណើរការ ដែលបុគ្គលអនុវត្តដើម្បីឆ្ពោះទៅកាន់ការបង្ហាញយេនឌ័រ និង/ឬរូបភាពរបស់ខ្លួនស្របទៅតាមអត្តសញ្ញាណយេនឌ័ររៀងៗខ្លួន។ វាគឺជាដំណើរការមួយដ៏ស្មុគស្មាញ និងលំបាកក្នុងការឆ្លងកាត់ ដែលត្រូវការប្រើពេលវេលា និងមានភាពខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ការផ្លាស់ប្តូរនេះរួមមាន៖<br>⇨ **ការផ្លាស់ប្តូរសង្គមរស់នៅ (Social transition)** ៖ ការប្រាប់ក្រុមគ្រួសារ មិត្តភ័ក្តិ និងមិត្តរួមការងារអំពីអត្តសញ្ញាណយេនឌ័ររបស់ខ្លួន ការប្រើឈ្មោះ ឬប្រើសព្វនាមថ្មីសម្រាប់ហៅខ្លួនឯង ការចាប់ផ្តើមទំលាប់ថ្មី ឬបញ្ឈប់ទំលាប់ចាស់ (ការប្តូរការស្លៀកពាក់ ការប្រើគ្រឿងសម្អាង និងគ្រឿងអលង្ការ ។ល។) ជាដើម ។<br>⇨ **ការផ្លាស់ប្តូរតាមបែបវេជ្ជសាស្ត្រ (Medical transition)** ៖ ការប្រើអរម៉ូន និង/ឬការវះកាត់ប្តូរភេទ។ |
| និន្នាការផ្លូវភេទ<br>**(Sexual Orientation)**<br> | និន្នាការផ្លូវភេទ ឬទំនោរផ្លូវភេទ សំដៅទៅលើការទាក់ទាញទាំងផ្លូវកាយ (ចង់ណេបនិត្យផ្លូវកាយ) និងផ្លូវចិត្ត(ចង់សាងទំនាក់ទំនង) ទៅលើនរណាម្នាក់ ឬទៅលើយេនឌ័រណាមួយ។ អ្នកអាចសម្គាល់បាននៅពេលដែលអ្នកមានអារម្មណ៍លង់ស្រលាញ់ ឬចាប់អារម្មណ៍នរណាម្នាក់ ។ | និន្នាការផ្លូវភេទមានលក្ខណៈជាឯកជនភាព និងមានភាពចម្រុះ ដែលអាចមានទំនោរទៅលើយេនឌ័រមួយ ឬច្រើនរួមមាន៖<br>⇨ និន្នាការទៅលើភេទផ្ទុយគ្នា និន្នាការទៅលើភេទដូចគ្នា និន្នាការទៅលើទាំងពីរភេទ (ទាំងបុរស និងស្ត្រី) និងទៅលើយេនឌ័រផ្សេងទៀត ឬគ្រប់យេនឌ័រ។<br>⇨ និន្នាការផ្លូវភេទរបស់បុគ្គលខ្លះ គឺមានត្រឹមតែមនោសញ្ចេតនា និងអារម្មណ៍ស្រលាញ់តែប៉ុណ្ណោះ ដែលអាចជាគ្មានអារម្មណ៍ផ្លូវភេទ ឬក៏មានដែរតែតិចតួច ឬក៏កើតមានដោយអាស្រ័យលក្ខខណ្ឌណាមួយតែប៉ុណ្ណោះ ដែលគេហៅថា ***អភេទនិយម*** ។ |
| ភេទជីវសាស្ត្រ<br>**(Biological sex)**<br> | ភេទជីវសាស្ត្រ សំដៅលើកត្តាជីវសាស្ត្រទាំងឡាយ (រូបរាងកាយ ក្រពេញ និងសរីរាង្គផ្លូវភេទ អរម៉ូនសូមក្រូម៉ូ និងដំណើរការផ្សេងៗនៃសរីរាង្គ) ដែលបង្កើតជាភាពខុសគ្នាខាងផ្នែកជីវសាស្ត្ររវាងប្រុស និងស្រី។ ភេទជាធម្មតាត្រូវបានកំណត់តាំងពីកំណើតក្នុងផ្ទៃម្តាយមកម្លេះ និងមិនទាន់មានវិធីសាស្ត្រណាមួយដែលអាចផ្លាស់ប្តូរភេទបានទាំងស្រុងនោះទេ។ | ភេទជីវសាស្ត្ររួមមាន៖<br>⇨ ***ភេទប្រុស និងភេទស្រី***<br>⇨ ***អន្តរភេទ៖*** គឺជាពាក្យទូទៅដែលប្រើសម្រាប់ស្ថានភាពផ្សេងៗដែលមនុស្សម្នាក់កើតមកជាមួយប្រដាប់បន្តពូជ ឬអវៈយវៈភេទដែលមិនអាចសម្គាល់បានថាជា "ស្រី" ឬ "បុរស"។ |

រៀបរៀងដោយ៖

អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់)
REPRODUCTIVE HEALTH ASSOCIATION OF CAMBODIA (RHAC)

គាំទ្រដោយ៖

rfsu

IPPF International Planned Parenthood Federation

© 2024 រក្សាសិទ្ធិគ្រប់យ៉ាងដោយ រ៉ាក់-RHAC